សេចក្តីព្រាង

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## សុន្ទរកថា
## ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុង
## ឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩

ថ្ងៃអាទិត្យ ៥កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
សាលសន្និសីទចតុមុខ, ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩

**"ទាំងអស់គ្នាចូលរួមជាចរន្តជាតិមួយ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍"**

- សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា ថ្នាក់ដឹកនាំក្រសួង ក្រសួងស្ថាប័នរាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ តំណាងអង្គទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជា
- លោកស្រី Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា
- ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ និងអន្តរជាតិ ព្រមទាំងក្មួយៗទាំងអស់ជាទីទាំងអស់ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំព្រះករុណា ខ្ញុំពិតជាមានកិត្តិយសបំផុត និង មានសេចក្តីសោមនស្សរីករាយក្រៃលែង ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និង អន្តរជាតិ ក្មួយៗ នៅក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩ ដ៏មហោឡារិកនាពេល

នេះ ។ នេះក៏ជាឱកាសមួយដែលអនុញ្ញាតឱ្យរូបខ្ញុំផ្ទាល់មានឱកាសបានសម្តែងនូវការកោតសរសើរដ៏ជ្រាលជ្រៅ ជូនចំពោះអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្រោមការដឹកនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ដែលបានសម្រេចនូវសមិទ្ធផលធំៗជាច្រើនក្នុងកាត់បន្ថយការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។ ជាមួយនេះ ខ្ញុំក៏សូមថ្លែងនូវការកោតសរសើរផងដែរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនជនរួមជាតិទាំងអស់ ដែលជាសកម្មជនប្រយុទ្ធនឹងជំងឺអេដស៍ជាតិ និងអន្តរជាតិគ្រប់លំដាប់ថ្នាក់នៅទូទាំងប្រទេស ដែលបានខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈមោះមុត ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ធ្វើការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ប្រកបដោយជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ ។ យើងពិតជាមានក្តីសង្ឃឹមថាយើងអាចធ្វើដំណើរឆ្ពោះទៅសម្រេចបាននូវគោលដៅសូន្យបី និងគោលដៅ ៩៥ ៩៥ ៩៥ នាឆ្នាំ២០២៥ ខាងមុខនេះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវៗជាទីរាប់អាន!**

វឌ្ឍនៈភាព ប្រសិទ្ធភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍តាមរយៈរបាយការណ៍សង្ខេបលើកឡើងដោយ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លោកស្រី Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា លោក **ជួប សុខចំរើន** តំណាងអង្គការសង្គមស៊ីវិលនៃគណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ រួមទាំងចំណាប់អារម្មណ៍របស់តំណាងបងប្អូនគ្រួសាររងគ្រោះដោយសារមេរោគអេដស៍នាពេលមុននេះ គឺជាភ័ស្តុតាងមួយយ៉ាងពិតប្រាកដ ដែលសបញ្ជាក់ច្បាស់ថា ទស្សនៈរបស់យើងក្នុងការកសាងសង្គមមួយដែលគ្មានការគំរាមកំហែងពីមេរោគអេដស៍និងជំងឺអេដស៍ អាចធ្វើទៅបាន និងមានន័យថាកម្ពុជាកំពុងតែស្ថិតនៅលើផ្លូវត្រូវ ដែលនឹងឈានទៅសម្រេចបាននូវ "គោលដៅ ៩៥ ៩៥ ៩៥" គឺ ៩៥%នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ៩៥%នៃអ្នកដែលដឹងស្ថានភាពផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង ៩៥%នៃអ្នកដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទទួលបានប្រសិទ្ធភាពខ្ពស់ ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួនដូចបានកំណត់ត្រឹមឆ្នាំ២០២៥ នៅក្នុងប្រទេសយើង និង នៅត្រឹមឆ្នាំ២០៣០ ដោយអង្គការសហប្រជាជាតិ។

របាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០១៩នេះ បានបង្ហាញថាកម្ពុជាបានកាត់បន្ថយការចម្លងមេរោគអេដស៍ថ្មី បានពី២.៣០០នាក់ក្នុងឆ្នាំ២០១០ មកត្រឹមចំនួនប៉ាន់ស្មានប្រហែល៨៨០នាក់ក្នុងឆ្នាំ២០១៨។ លើសពីនេះទៅទៀត កម្ពុជាអាចផ្តល់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ទៅដល់អ្នកផ្ទុកមេរោគអេដស៍និងជំងឺអេដស៍ដែលកំពុងត្រូវការការព្យាបាលបានរហូតដល់ទៅ៩៩% ដែលជាលទ្ធផលបានធ្វើឱ្យអត្រាមរណៈភាពដោយសារជំងឺអេដស៍បន្តធ្លាក់ចុះជារៀងរាល់ឆ្នាំ។ អត្រាធ្វើតេស្តរកមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះបានកើនឡើងខ្ពស់។ អត្រាចម្លងពីម្តាយដែលមានផ្ទុកមេរោគអេដស៍ទៅកូន និងសន្ទស្សន៍នៃការរើសអើង មើលងាយអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ មានការថយចុះខ្លាំងគួរជាទីមោទនៈ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវៗជាទីរាប់អាន!**

## សេចក្តីព្រាង

ទោះបីជាប្រទេសកម្ពុជាយើងកំពុងទទួលបានជោគជ័យជាបន្តបន្ទាប់ ដ៏គួរឱ្យកត់សម្គាល់ក៏ពិតមែន ក៏ស្ថានភាពជោគជ័យរបស់យើងនាពេលនេះ នៅមានភាពផុយស្រួយនៅឡើយ ។ ក្នុងន័យនេះ ប្រសិនបើយើងធ្វេសប្រហែសតែបន្តិច ការរាលដាលមេរោគអេដស៍នឹងអាចផ្ទុះឡើងវិញ ដែលពិបាកនឹងគ្រប់គ្រងជាងពេលមុនៗ ទៅទៀត ។ ជាពិសេស ការផ្ទុះឡើង នៅក្នុងចំណោមប្រជាជនប្រឈមមុខខ្ពស់ រួមមាន ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ក្រុមអ្នកប្រើប្រាស់ និងចាក់គ្រឿងញៀន ក្រុមស្ត្រីបម្រើការងារក្នុងគ្រឹះស្ថានកំសាន្តសប្បាយ ក្រុមយុវវ័យ ក្រុមប្រជាជនចំណាកស្រុក ជាដើម។ អាស្រ័យហេតុនេះ សូមជនរួមជាតិទាំងអស់បន្តការយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការបង្ការខ្លួនជាប់ជានិច្ចពីការចម្លងមេរោគអេដស៍ និងបន្តចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល ឆ្ពោះទៅបញ្ចប់ការរាលដាលមេរោគអេដស៍និងជំងឺអេដស៍នាឆ្នាំ២០២៥។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗជាទីរាប់អាន!**

របៀបវារៈនៃការប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីឈានទៅសម្រេចបាននូវគោលដៅសូន្យបី នាឆ្នាំ២០២៥ គឺមិនមែនជាការងាយស្រួលនោះទេ តែក៏មិនមែនមានន័យថាយើងធ្វើមិនបាននោះដែរ គ្រាន់តែទាមទារនូវការដឹកនាំ ការគ្រប់គ្រង ការសម្របសម្រួល និងការចូលរួមប្រកបដោយការប្តេជ្ញាចិត្តយ៉ាងមោះមុតរួមគ្នានិងជម្នះឱ្យបាននូវរាល់ឧបសគ្គនានា ដែលរារាំងដល់ការធ្វើអន្តរាគមន៍របស់យើងតែប៉ុណ្ណោះ ដូចជាកត្តារើសអើង កត្តាធនធាន កត្តាបច្ចេកវិទ្យាជាដើម។ ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រកាសជាឱឡារិកថា រាជរដ្ឋាភិបាលកម្ពុជាក្នុងឋានៈជាសមាជិកមួយរូបនៃអង្គការសហប្រជាជាតិ បានចូលរួមរៀបចំ និងសម្រេចរួចទៅហើយ នាកិច្ចប្រជុំកំពូលមហាសន្និបាតវិសាមញ្ញអង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍ឆ្នាំ២០១៦ នាបូរី ញ៉ូវយ៉ក ក្នុងការដាក់ចេញនូវ "សេចក្តីថ្លែងការណ៍ថ្មីស្តីពីការសម្រេចចិត្តជានយោបាយក្នុងការឈានទៅលុបបំបាត់ជំងឺអេដស៍នៅត្រឹមឆ្នាំ២០៣០"។ ដូច្នេះយុទ្ធនាការប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា គឺនៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ជាពិសេស គឺកម្ពុជាបានបង្ហាញច្បាស់ពីការប្តេជ្ញាចិត្តក្នុងការលុបបំបាត់ជំងឺ អេដស៍នៅឲ្យបាននៅឆ្នាំ២០២៥ ។ ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជា នឹងបន្តពិនិត្យលទ្ធភាពក្នុងការបង្កើននូវធនធានថវិកាជាតិឱ្យបានកាន់តែច្រើនថែមទៀតពី២៤% នៃចំណាយសរុបនាឆ្នាំ២០១៧ ហូតដល់៥០% នាឆ្នាំ២០២៣ ដើម្បីបំពេញសេចក្តីត្រូវការចាំបាច់ក្នុងការពង្រីកអត្រាគ្របដណ្តប់ទៅលើភូមិសាស្ត្រ ទៅលើក្រុមគោលដៅ និងទៅលើសេវាឱ្យបានគ្រប់ជ្រុងជ្រោយ និងឱ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ជាពិសេសការរួមវិភាគទានលើការទិញឱសថប្រឆាំងមេរោគអេដស៍ ដែលជួយសង្គ្រោះជីវិតអ្នករស់នៅជាមួយមេរោគអេដស៍បានរាប់ម៉ឺននាក់។

ឆ្លៀតក្នុងឱកាសចូលរួមអបអរសាទរទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០១៩ នេះ ខ្ញុំសូមចូលរួមផ្តល់នូវសារមួយចំនួន ជូនជនរួមជាតិដូចខាងក្រោម៖

## សេចក្តីព្រាង

ទី ១. ចូលរួមអនុវត្តដោយម៉ឺងម៉ាត់ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ ដែលជាផែនទីចង្អុលផ្លូវតែមួយគត់សម្រាប់ការងារប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាដែលដឹកនាំអនុវត្តដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដោយផ្អែកលើសសរស្តម្ភទាំងបី រួមមាន ១. ការដឹកនាំ និងភាពជាម្ចាស់ ២. ភាពជាដៃគូ និង ៣. ការវិនិយោគ ដើម្បីជានាភាពជោគជ័យ និងនិរន្តរភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ទី ២. សូមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យលទ្ធភាពបន្ត និងពង្រីកការផ្តល់ថវិកាសម្រាប់ការងារអេដស៍ និងសូមក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ចូលរួមអនុវត្តឱ្យបានកាន់តែខ្លាំងក្លាបន្ថែមទៀតនូវវិធានការទាំងប្រាំមួយ ដូចមានចែងក្នុងលិខិតលេខ ២១៣ សជណ.សស ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ទី ៣. សូមក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្រុក ខណ្ឌ ជាពិសេសឃុំ សង្កាត់ត្រូវតែរៀបចំផែនការសកម្មភាព និងលើកសេចក្តីព្រាងថវិកាដើម្បីបង្កើនការចូលរួមឆ្លើយតបឱ្យបានទ្វេដង ទូលំទូលាយ គ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលាទៅនឹងការរាលដាលមេរោគអេដស៍របស់ខ្លួន យោងទៅតាមគម្រោងផែនការយុទ្ធសាស្ត្រទូលំទូលាយ និងពហុវិស័យលើកទី៥ ក្រោមការជួយសម្របសម្រួលពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋអំណាចគ្រប់លំដាប់ថ្នាក់។

ទី ៤. សូមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង និង ស្ថាប័នពាក់ព័ន្ធពង្រីកពង្រឹងកិច្ចសហប្រតិបត្តិការជាមួយកាកបាទក្រហមកម្ពុជាលើការងារឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ ដើម្បីបង្ការការឆ្លងថ្មីនៃមេរោគអេដស៍ ជាពិសេសការអន្តរាគមន៍ ដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការឈានទៅសម្រេចឱ្យបាននូវការកាត់ផ្តាច់ទាំងស្រុងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងលុបបំបាត់ទាំងស្រុងការរើសអើងមាក់ងាយទៅលើអ្នករងគ្រោះដោយសារជំងឺអេដស៍នៅត្រឹមឆ្នាំ ២០២៥។

ទី ៥. សូមបងប្អូនសហគមន៍នៃអ្នកផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍ ក្រុមប្រឈមមុខខ្ពស់នៃការឆ្លងមេរោគអេដស៍ អ្នកស្ម័គ្រចិត្តសុខភាពភូមិ មេភូមិ មេឃុំ ចៅសង្កាត់នៅថ្នាក់មូលដ្ឋានទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងធ្វើការរួមគ្នា សហការគ្នា ដើម្បីទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងដោះស្រាយផលប៉ះពាល់ដែលបណ្តាលមកពីបញ្ហាអេដស៍ ដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្សសមភាពយេនឌ័រ និងមិនទុកឱ្យនរណាម្នាក់ចោល ដោយមិនបានទទួលបាននូវសេវាបង្ការ ថែទាំព្យាបាល និងគាំទ្រដែលពួកគេត្រូវការនោះឡើយ ។

ទី ៦. ទាំងអស់គ្នា គ្រប់ស្ថាប័នពាក់ព័ន្ធ គ្រប់សហគមន៍នៃប្រជាជនគន្លឹះ ត្រូវយកចិត្តទុកដាក់គ្រប់គ្រងឱ្យបានទ្វេដង នូវការកាត់បន្ថយការចម្លងមេរោគ អេដស៍ក្នុងចំណោមក្រុមប្រឈមខ្ពស់នឹងការចម្លងមេរោគអេដស៍ រួមមាន ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ក្រុមអ្នកប្រើប្រាស់ និងចាក់

**សេចក្តីព្រាង**

គ្រឿងញៀន ក្រុមស្ត្រីបម្រើការងារក្នុងគ្រឹះស្ថានកំសាន្តសប្បាយក្រុមយុវវ័យ ក្រុមប្រជាជនចំណាកស្រុក ជាដើម តាមរយៈវិធានការ "ឆាប់ធ្វើតេស្ត ឆាប់ដឹង ឆាប់ព្យាបាល" ។

ទី ៧. សូមបងប្អូនប្រជាពលរដ្ឋ ប្រើប្រាស់ស្រោមអនាម័យ ឱ្យបានកាន់តែទូលំទូលាយព្រោះថាស្រោមអនាម័យ គឺនៅតែជាមធ្យោបាយប្រកបដោយប្រសិទ្ធិភាពខ្ពស់បំផុតក្នុងការបង្ការការចម្លងមេរោគអេដស៍ មេរោគកាមរោគ ការពន្យារកំណើត។ ជាមួយនោះ ខ្ញុំសូមបញ្ជាក់ថា ស្រោមអនាម័យតែមួយ មិនអាចលើកយកមកធ្វើជាភ័ស្តុតាងក្នុងការចោទប្រកាន់លើអំពើជួញដូរផ្លូវភេទនោះទេ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗជាទីរាប់អាន!**

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូនអង្គពិធីទាំងមូល នូវពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀតជូនជាតិ មាតុភូមិ នាឆ្នាំខាងមុខនេះ និងសូមប្រកាសជាឱឡារិកថា "**ទាំងអស់គ្នាចូលរួមជាចលនាជាតិមួយ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍**!"។

*សូមអរព្រះគុណ និងអរគុណ!*